**សន្លឹកព័ត៌មានស្ដីពីវ៉ាក់សាំង**

# វ៉ាក់សាំងជំងឺអុតធំ/ជំងឺអុតស្វា (JYNNEOS™)៖ *អ្វីដែលអ្នកត្រូវដឹង*

Many Vaccine Information Statements are available in Khmer and other languages. See www.immunize.org/vis

សេចក្តីថ្លែងការណ៍នៃព័ត៌មានអំពីថ្នាំវ៉ាក់សាំងជាច្រើនគឺអាចរកបានជាភាសាខ្មែរ និងភាសាផ្សេងទៀត។ ចូលមើល www.immunize.org/vis

## 1. ហេតុអ្វីត្រូវចាក់វ៉ាក់សាំង?

**វ៉ាក់សាំងជំងឺអុតធំ/ជំងឺអុតស្វា** (JYNNEOS™) អាចជួយការពារប្រឆាំងនឹងជំងឺអុតធំ ជំងឺអុតស្វានិងជំងឺផ្សេងទៀតដែលបង្កដោយវីរុស Orthopoxviruses រួមទាំងវីរុស Vaccinia។

ជំងឺអុតធំគឺជាជំងឺធ្ងន់ធ្ងរបង្កដោយវីរុស Variola។ មនុស្សមួយចំនួនបន្តស្ថិតក្រោមហានិភ័យនៃការប៉ះពាល់ទៅនឹងវីរុសដែលបង្កជំងឺអុតធំ រួមមានអ្នកដែលធ្វើការនៅក្នុងការត្រៀមសង្គ្រោះបន្ទាន់ និងបុគ្គលិកមន្ទីរពិសោធន៍មួយចំនួន។ វីរុសអាចរាលដាលពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ដោយបង្កជារោគសញ្ញាដូចជា ក្តៅខ្លួន និងឡើងរមាស់លើស្បែក។ មនុស្សជាច្រើនដែលកើតជំងឺអុតធំកន្លងមកបានជាសះស្បើយ ប៉ុន្តែមានប្រហែលជា 3 ក្នុងចំណោម 10 នាក់ដែលកើតជំងឺនេះបានស្លាប់។

ជំងឺអុតស្វាគឺជាជំងឺកម្រមួយដែលមានរោគសញ្ញាស្រដៀងគ្នាដែរប៉ុន្តែមានសភាពស្រាលជាងរោគសញ្ញាជំងឺអុតធំ។ យ៉ាងណាមិញ ជំងឺអុតស្វាអាចបង្កឱ្យស្លាប់បាន។ ជំងឺអុតស្វាគឺជាមេរោគឆ្លងដែលបង្ហាញខ្លួននៅក្នុងទ្វីបអាហ្វ្រិក ហើយករណីរាតត្បាតនាំចូលនៃជំងឺអុតស្វាជួនកាលកើតមាននៅប្រទេសផ្សេងទៀត រួមទាំងប្រទេសអាមេរិកផងដែរ។

វីរុស Vaccinia អាចបង្កជាជំងឺបាននៅពេលមនុស្សប៉ះពាល់ជាមួយមនុស្សឆ្លងមេរោគ (ដូចជាការប៉ះពាល់ជាមួយនរណាម្នាក់ដែលទើបទទួលបានវ៉ាក់សាំង ACAM2000®, ដែលជាប្រភេទវ៉ាក់សាំងជំងឺអុតធំមួយប្រភេទទៀត) ឬសត្វ។ អ្នកដែលធ្វើការជាមួយវីរុស Vaccinia នៅក្នុងមន្ទីរពិសោធន៍អាចនឹងប៉ះពាល់ដោយអចេតនាទៅលើវីរុស ហើយប្រសិនបើពួកគេឆ្លង នោះពួកគេនឹងមានជំងឺ។ យ៉ាងណាមិញការចម្លងរបស់វីរុស Vaccinia ភាគច្រើននឹងជាដោយឯកឯងវិញដោយមិនត្រូវការព្យាបាល។

## 2. វ៉ាក់សាំងជំងឺអុតធំ/ជំងឺអុតស្វា (JYNNEOS™)

វ៉ាក់សាំងជំងឺអុតធំ/ជំងឺអុតស្វា (JYNNEOS™) ត្រូវបានផលិតឡើងដោយប្រើវីរុស Vaccinia មានជីវិតដែលបានធ្វើឱ្យខ្សោយ ហើយមិនអាចបង្កជំងឺអុតធំ ជំងឺអុតស្វា ឬមេរោគចម្លងដទៃទៀតឡើយ។

JYNNEOS™ ត្រូវបានអនុញ្ញាតដាក់ឱ្យប្រើប្រាស់ដោយ Food and Drug Administration (FDA) សម្រាប់ការបង្ការជំងឺអុតធំនិងអុតស្វាលើ **មនុស្សពេញវ័យចាប់ពីអាយុ 18 ឆ្នាំដែលមានហានិភ័យខ្ពស់ក្នុងការឆ្លងជំងឺអុតធំ ឬអុតស្វា។**

- CDC បានណែនាំ JYNNEOS™ ដល់បុគ្គលិកមន្ទីរពិសោធន៍ និងសមាជិកក្រុមឆ្លើយតបសង្គ្រោះបន្ទាន់ដែលអាចនឹងប៉ះពាល់វីរុស ដែលអាចបង្កជាការឆ្លងវីរុស Orthopoxvirus។
- CDC បានណែនាំឱ្យប្រើវ៉ាក់សាំងសម្រាប់អ្នកដែលគ្រប់គ្រង ACAM2000®, ឬអ្នកដែលថែទាំអ្នកជំងឺដែលឆ្លងវីរុស Orthopoxviruses។

JYNNEOS™ ជាធម្មតាត្រូវបានផ្តល់ជូនជាស៊េរីនៃការចាក់ចំនួន 2 ដងដោយគម្លាតពីគ្នា 4 សប្តាហ៍។ អ្នកដែលបានទទួលវ៉ាក់សាំងជំងឺអុតធំរួចហើយពីអតីតកាល អាចនឹងត្រូវការតែ 1 ដូសប៉ុណ្ណោះ។

ដូសជំរុញត្រូវបានណែនាំឱ្យប្រើរៀងរាល់ 2 ឬ 10 ឆ្នាំ ប្រសិនបើបុគ្គលនោះនៅតែបន្តស្ថិតក្នុងហានិភ័យនៃការប៉ះពាល់ជំងឺអុតធំ អុតស្វា ឬវីរុស orthopoxviruses ផ្សេងទៀត។ អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកអាចផ្តល់ព័ត៌មានបន្ថែមដល់អ្នកបាន។

## 3. ប្រឹក្សាជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក

ប្រាប់អ្នកផ្តល់វ៉ាក់សាំងរបស់អ្នក ប្រសិនបើបុគ្គលដែលទទួលវ៉ាក់សាំងនោះ៖

- **មានប្រតិកម្មអាឡែហ្ស៊ីបន្ទាប់ពីដូសវ៉ាក់សាំងជំងឺអុតធំកាលពីលើកមុន ឬមានអាឡែហ្ស៊ីធ្ងន់ធ្ងរដែលគំរាមកំហែងដល់អាយុជីវិត**
- **មានប្រព័ន្ធភាពស៊ាំចុះខ្សោយ**
- មានផ្ទៃពោះ ឬគិតថាពួកគេអាចនឹង**មានផ្ទៃពោះ ឬកំពុងបំបៅដោះ**

ក្នុងករណីមួយចំនួន អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកអាចនឹងសម្រេចផ្អាកការផ្តល់វ៉ាក់សាំងជំងឺអុតធំ/ជំងឺអុតស្វាតាមទម្លាប់ (ការប៉ះពាល់មុន) នៃវ៉ាក់សាំង JYNNEOS™ រហូតដល់ការជួបនៅពេលខាងមុខ។

អ្នកដែលមានជំងឺស្រាល ដូចជាជំងឺផ្តាសាយ អាចទទួលថ្នាំបង្ការនេះបាន អ្នកដែលមានជំងឺកម្រិតមធ្យម ឬធ្ងន់ជាធម្មតាគួរតែរង់ចាំរហូតដល់ពួកគេជាសះស្បើយ មុនទទួលដូសតាមទម្លាប់ (ការប៉ះពាល់មុន) នៃវ៉ាក់សាំង JYNNEOS™។ **ប្រសិនបើអ្នកត្រូវបានណែនាំឱ្យទទួលវ៉ាក់សាំង JYNNEOS™ ដោយសារការប៉ះពាល់វីរុសជំងឺអុតស្វា នោះអ្នក**

U.S. Department of Health and Human Services
Centers for Disease Control and Prevention

**គួរតែទទួលយកវ៉ាក់សាំង ដោយមិនចាំបាច់គិតអំពីជំងឺ ការមានផ្ទៃពោះ ការបំបៅដោះ ឬប្រព័ន្ធភាពស៊ាំចុះខ្សោយ ដែលកើតមានស្របពេលគ្នានេះទេ។**

JYNNEOS™ ជាធម្មតាអាចនឹងត្រូវបានផ្តល់ឱ្យដោយមិនគិតអំពីពេលវេលានៃវ៉ាក់សាំងផ្សេងទៀតឡើយ។ យ៉ាងណាមិញ មនុស្សមួយចំនួនដែលស្ថិតក្នុងហានិភ័យកាន់តែខ្ពស់នៃស្ថានភាពមួយដែលហៅថា Myocarditis (ការហើមសាច់ដុំបេះដូង) រួមទាំងមនុស្សវ័យជំទង់ និងបុរសពេញវ័យវ័យក្មេង អាចនឹងត្រូវពិចារណាធ្វើការរង់ចាំ 4 សប្តាហ៍បន្ទាប់ពីទទួលវ៉ាក់សាំង JYNNEOS™ មុនពេលទទួលវ៉ាក់សាំង COVID-19 មួយចំនួន។ **ប្រសិនបើអ្នកត្រូវបានណែនាំឱ្យទទួលវ៉ាក់សាំង JYNNEOS™ ដោយសារតែការប៉ះពាល់វីរុសជំងឺអុតស្វា នោះអ្នកគួរតែទទួលយកវ៉ាក់សាំងនេះ បើទោះបីជាអ្នកទើបបានទទួលវ៉ាក់សាំង COVID-19 នាពេលថ្មីៗក៏ដោយ។**

## 4. ហានិភ័យប្រតិកម្មវ៉ាក់សាំង

- ការឡើងក្រហមលើស្បែក ការឈឺចាប់ ការហើម និងការរមាស់នៅកន្លែងចាក់វ៉ាក់សាំងគឺជាបញ្ហាទូទៅបំផុតដែលកើតមានបន្ទាប់ពីចាក់វ៉ាក់សាំង JYNNEOS™។
- ការអស់កម្លាំង (ល្ហើយ) ឈឺក្បាល និងឈឺសាច់ដុំ ក៏អាចកើតមានពេលខ្លះផងដែរ បន្ទាប់ពីចាក់វ៉ាក់សាំង JYNNEOS™។

ពេលខ្លះ មនុស្សសន្លប់បន្ទាប់ពីនីតិវិធីវេជ្ជសាស្ត្ររួមទាំងការចាក់វ៉ាក់សាំង។ សូមប្រាប់អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក ប្រសិនបើអ្នកវិលមុខ ឬចក្ខុញ្ញាណផ្លាស់ប្តូរ ឬឮសំឡេងហឹងក្នុងត្រចៀក។

ដូចឱសថផ្សេងទៀតដែរ វ៉ាក់សាំងនេះកម្រនឹងបង្កប្រតិកម្មអាឡែហ្ស៊ីធ្ងន់ធ្ងរ របួសធ្ងន់ធ្ងរផ្សេងទៀត ឬធ្វើឲ្យស្លាប់បាត់បង់ជីវិតណាស់។

អ្នកអាចចុះឈ្មោះក្នុង V-safe បន្ទាប់ពីទទួលដូសណាមួយនៃវ៉ាក់សាំង JYNNEOS™ ដោយប្រើទូរសព្ទរបស់អ្នក ហើយចូលទៅកាន់ vsafe.cdc.gov។ V-safe គឺជាប្រព័ន្ធត្រួតពិនិត្យសុវត្ថិភាពដែលអនុញ្ញាតឱ្យអ្នកចែករំលែកជាមួយ CDC អំពីសុខភាពរបស់អ្នក ឬអ្នកនៅក្នុងបន្ទុករបស់អ្នកបន្ទាប់ពីទទួលវ៉ាក់សាំង JYNNEOS™។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់ www.cdc.gov/vsafe។

## 5. ចុះប្រសិនជាមានបញ្ហាធ្ងន់ធ្ងរវិញនោះ?

ប្រតិកម្មអាឡែហ្ស៊ីអាចកើតមានបន្ទាប់ពីអ្នកដែលបានចាក់វ៉ាក់សាំងចាកចេញពីគ្លីនិក។ ប្រសិនបើអ្នកឃើញសញ្ញានៃប្រតិកម្មអាឡែហ្ស៊ីធ្ងន់ធ្ងរ (កន្ទួលក្រហម ហើមមុខនិងបំពង់ក ពិបាកដកដង្ហើម បេះដូងលោតញាប់ វិលមុខ ឬខ្សោយ) សូមទូរសព្ទទៅលេខ **9-1-1** និងនាំបុគ្គលនោះទៅមន្ទីរពេទ្យដែលនៅជិតបំផុត។

Khmer translation provided by Immunize.org

សម្រាប់សញ្ញាផ្សេងទៀតដែលធ្វើឱ្យអ្នកបារម្ភ សូមទូរសព្ទទៅអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក។

ប្រតិកម្មអវិជ្ជមានទាំងឡាយគួរធ្វើការរាយការណ៍ទៅប្រព័ន្ធ Vaccine Adverse Event Reporting System (VAERS) (ប្រព័ន្ធរាយការណ៍ផលអាក្រក់នៃវ៉ាក់សាំង)។ អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកជាធម្មតានឹងដាក់របាយការណ៍នេះ ឬអ្នកក៏អាចធ្វើវាដោយខ្លួនឯងបានដែរ។ សូមចូលទៅគេហទំព័រ VAERS តាមរយៈ www.vaers.hhs.gov ឬទូរសព្ទទៅលេខ **1-800-822-7967**។ *VAERS គឺសម្រាប់តែការរាយការណ៍អំពីប្រតិកម្មប៉ុណ្ណោះ ហើយបុគ្គលិក VAERS មិនផ្តល់ជូនការប្រឹក្សាវេជ្ជសាស្ត្រនោះទេ។*

## 6. កម្មវិធីផ្តល់សំណងការរងរបួសវិធានទប់ស្កាត់

កម្មវិធី Countermeasures Injury Compensation Program គឺជាកម្មវិធីសហព័ន្ធដែលអាចជួយបង់ប្រាក់សម្រាប់ការថែទាំវេជ្ជសាស្ត្រ និងការចំណាយជាក់លាក់ផ្សេងទៀតរបស់មនុស្សមួយចំនួនដែលរងរបួសធ្ងន់ធ្ងរដោយសារវ៉ាក់សាំង ឬឱសថមួយចំនួន។ ប្រសិនបើអ្នករងរបួសដោយសារវ៉ាក់សាំងជំងឺអុតធំ/អុតស្វា អ្នកអាចស្វែងយល់បន្ថែមអំពីកម្មវិធីនេះដោយចូលទៅកាន់គេហទំព័ររបស់កម្មវិធីតាមរយៈ www.hrsa.gov/cicp, ឬទូរសព្ទទៅលេខ **1-855-266-2427 (855-266-CICP)**។

## 7. តើខ្ញុំអាចស្វែងយល់បន្ថែមដោយរបៀបណា?

- សូមសួរអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក។
- សូមទូរសព្ទទៅក្រសួងសុខាភិបាលរដ្ឋ ឬនៅមូលដ្ឋានរបស់អ្នក។
- សូមចូលទៅកាន់គេហទំព័ររបស់ Food and Drug Administration (FDA) ដើម្បីទទួលបានឯកសារព័ត៌មានក្នុងកញ្ចប់វ៉ាក់សាំង ឬទទួលព័ត៌មានបន្ថែមតាមរយៈ: www.fda.gov/vaccines-blood-biologics/vaccines។
- Centers for Disease Control and Prevention (CDC) (មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺ)៖
  - សូមទូរសព្ទទៅលេខ **1-800-232-4636 (1-800-CDC-INFO)** ឬ
  - ចូលទៅកាន់គេហទំព័ររបស់ CDC តាមរយៈ: www.cdc.gov/poxvirus/monkeypox។